ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# បទបង្ហាញកម្មវិធីទី៣៖ ការពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

## ប្រធានបទ៖ ធានានិរន្តរភាពនៃប្រាក់ចំណូលគ្រួសារឆ្ពោះទៅកាន់សហគមន៍ជនបទស៊ីវិល័យ



បទបង្ហាញដោយ៖ ឯកឧត្តម **ជ្រាយ ម៉ុម** អគ្គនាយកបច្ចេកទេស

ថ្ងៃអង្គារ-ពុធ ១០-១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ថ្ងៃទី១៩-២០ ខែមីនា ឆ្នាំ ២០២៣

# មាតិកា


១. សេចក្តីផ្តើម

២. សមិទ្ធផលសំខាន់ៗ សម្រេចបានក្នុងឆ្នាំ ២០២៣

៣. បញ្ហាប្រឈម

៤. វិធានការដោះស្រាយ

៥. មេរៀន និងបទពិសោធន៍

៦. ទិសដៅការងារបន្ត

៧. សន្និដ្ឋាន

# ១. សេចក្តីផ្តើម



បង្កើតការងារ និងមុខរបរ

សហគ្រិនភាព

ពិពិធកម្ម សេដ្ឋកិច្ចជនបទ

ការអភិវឌ្ឍភូមិគំរូ

សហគមន៍ជនបទស៊ីវិល័យ

ការបណ្តុះបណ្តាល វិជ្ជាជីវៈ

ការផ្តល់ឥណទានជនបទ សកម្មភាពសេដ្ឋកិច្ច

# ២. សមិទ្ធផលសំខាន់ៗ សម្រេចបានក្នុងឆ្នាំ២០២៣

## កម្មវិធីទី៣ បាននឹងកំពុងដើរតួយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច គ្រួសារនៅជនបទ លើការងារមួយចំនួនដូចជា៖

- ការងារលើកកម្ពស់សន្តិសុខស្បៀង
- ការអភិវឌ្ឍន៍ភូមិចម្រុះ
- ការពង្រឹងសមត្ថភាពគណៈកម្មធិការអភិវឌ្ឍន៍ភូមិ
- ការអប់រំក្រៅប្រព័ន្ធ
- ការផ្តល់ឥណទានសាច់ប្រាក់និងឥណទានសត្វ
- ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងសហគ្រិនភាព
- ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញចល័ត
- ការស្វែងរកនិងទំនាក់ទំនងទីផ្សារជូនកសិករ
- ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើម
- ការពង្រឹងសមត្ថភាពនិងអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច
- ការរៀបចំភូមិគំរូ

## ការបង្កើតការងារ និងមុខរបរនៅជនបទ

- បានរៀបចំសិក្ខាសាលា និងបណ្តុះបណ្តាលបាន ចំនួន២១ វគ្គ នឹងមាន សិក្ខាកាមចូលរួមមានចំនួន ៥០០នាក់។

## ការជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារនៅជនបទ

- បានរៀបចំសិក្ខាសាលា និងបណ្តុះបណ្តាលបាន ចំនួន០៤ វគ្គ នឹងមាន សិក្ខាកាមចូលរួមមានចំនួន ១៣៦នាក់ សាងសង់ផ្សារជនបទបានចំនួន ១ និងការតាំងពិពណ៌បង្ហាញផលិតផលបានចំនួន ១លើក។





## ការបណ្ដុះបណ្ដាលធនធានមនុស្ស និងជំនាញមូលដ្ឋាន

- បើកវគ្គបណ្ដុះបណ្ដាលស្ដីពីតួនាទី ភារកិច្ច គ.អ.ភ និងសញ្ញាណចលនាភូមិថ្មីក្នុងខេត្តគោលដៅចំនួន១២ បានចំនួន ៣៨វគ្គ ស្មើនឹង ២០២ភូមិ មានសិក្ខាកាមចូលរួមចំនួន ៦៨០នាក់ ស្រី ២០៨នាក់។
- បានផ្ដល់ការបណ្ដុះបណ្ដាលជំនាញមូលដ្ឋានរយៈពេលខ្លី និងវែងដោយឥតគិតថ្លៃ ចំនួន ១០០ វគ្គ ជូនប្រជាពលរដ្ឋក្រីក្រនៅជនបទ ជាពិសេសយុវជនចំនួន ២ ០៥៨ នាក់ (ស្រី ៨៨៦ នាក់) សម្រាប់បង្កើតមុខរបរ ឬការងារដែលអាចទទួលបានប្រាក់កម្រៃសមរម្យ។

## ការអភិវឌ្ឍន៍ចម្រុះសម្រាប់សហគមន៍ជនបទ

- បានជីកស្រះទឹកគ្រួសារចំនួន ៥០ស្រះ ក្នុងខេត្តគោលដៅចំនួន ៨ខេត្ត ស្មើនឹង ៨ភូមិ ៥០គ្រួសារ។ ផ្ដល់កូនឈើហូបផ្លែចម្រុះចំនួន ៤ ០០០ដើម និងពូជបន្លែចម្រុះចំនួន ៩ ០០០កញ្ចប់ ដល់គ្រួសារសរុបចំនួន ១ ២៨០គ្រួសារ។







## ការអភិវឌ្ឍន៍ និងអភិរក្សជនជាតិដើមភាគតិច

- បានចុះវាយតម្លៃកំណត់អត្តសញ្ញាណ និងចេញលិខិតទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចនៅខេត្តចំនួន ៣
- បានពន្លឿនការដោះស្រាយបញ្ហាក្នុងការកំណត់អត្តសញ្ញាណ ចំនួន ៦ភូមិ និងប្រជុំផ្សព្វផ្សាយស្តីពី នីតិវិធីដំណើរការកំណត់អត្តសញ្ញាណជនជាតិ កួយ នៅភូមិវាលវែង ឃុំឈូក និងភូមិអណ្តាស ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។









## ការលើកកម្ពស់ជីវភាពប្រជាជនជនបទ

- បើកវគ្គបណ្តុះបណ្តាលស្តីពី សួនដំណាំគ្រួសារនិងរបៀបធ្វើជីកំប៉ុស្ត បានចំនួន ៦វគ្គ ដល់ខេត្តគោលដៅចំនួន ២ខេត្ត សិក្ខាកាមចូលរួមចំនួន ១២០នាក់ ស្រី ៨៩នាក់ និងផ្តល់សម្ភារៈធ្វើរោងជីកំប៉ុស្តនិងពូជបន្លែចម្រុះដល់គ្រួសារចំនួន ៣១៥គ្រួសារ

## ការងារឥណទានជនបទ

- គិតត្រឹមខែកញ្ញា ឆ្នាំ២០២៣ ប្រតិបត្តិករថ្នាក់ខេត្តកំពុងអនុវត្តនិង សហការជាមួយដៃគូ មានទ្រព្យសកម្មសរុបចំនួន ២ ៣០១ ៧៩១ ១៤៥ រៀល ក្នុងនោះឥណទានក្នុងដៃអតិថិជនសរុបចំនួន ១ ៩២៨ ២៤០ ៦៧៥ រៀលមានអ្នកខ្ចីសរុបចំនួន ៨១៧ នាក់ ស្រីចំនួន ៥៧២ នាក់ នៅភូមិគោលដៅចំនួន ៨១ភូមិ ៤១ឃុំ ២៣ស្រុក ក្នុងខេត្តគោលដៅ ចំនួន ៩ខេត្ត។







# ៣.បញ្ហាប្រឈម

- តម្រូវការ និងការឆ្លើយតបក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទមិនទាន់សមាមាត្រនៅឡើយ
- ការប្រែប្រួលអាកាសធាតុ
- គម្លាតហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់
- ផ្នត់គំនិតរបស់ប្រជាពលរដ្ឋមួយចំនួននៅជនបទពឹងផ្អែកលើជំនួយ
- វិបត្តិបំណុល និងហិរញ្ញវត្ថុ
- កង្វះលទ្ធភាពក្នុងការចូលរួមការអភិវឌ្ឍគ្រប់វិស័យនៅតំបន់ជនជាតិដើមភាគតិច

# ៤. វិធានការដោះស្រាយ

ទី១÷ បន្តកៀរគរ និង ពង្រឹងកិច្ចសហការ ក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍នានាឱ្យកាន់តែប្រសើរឡើងថែមទៀត

ទី២÷ បន្តបណ្តុះបណ្តាល និងបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋនៅជនបទ និងផ្សព្វផ្សាយវិធីសាស្ត្រសមស្របដល់ប្រជាពលរដ្ឋដើម្បីផ្លាស់ប្តូរទម្លាប់ឥរិយាបទ និងកាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ។

ទី៣÷ ពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

ទី៤÷ ផ្សព្វផ្សាយបំផុសឱ្យមានការចូលរួមបន្ថែមទៀតពីបងប្អូនជាជនជាតិដើមភាគតិច ជាពិសេសយុវជន ដើម្បីឱ្យគាត់បានយល់ដឹងពីសារសំខាន់នៃការរក្សាបាននូវអត្តសញ្ញាណ និងអភិរក្សប្រពៃណី វប្បធម៌ របស់ពួកគាត់

# ៥. មេរៀន និងបទពិសោធន៍

## ១. ការអភិវឌ្ឍន៍សហគមន៍គំរូ

## ភូមិជម្ពូព្រឹក្ស

### ទីតាំងភូមិសាស្ត្រ

- ភូមិជម្ពូព្រឹកស្ថិតក្នុងឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។
- មានដីលំនៅស្ថាន ៤២ ហិចតា និងដីបង្កបង្កើនផលចំនួន ១០៥ ហិចតា
- ចម្ងាយប្រហែល ៧ គីឡូម៉ែត្រទៅសាលាស្រុក ៣ គីឡូម៉ែត្រទៅទីប្រជុំជន។

### សេដ្ឋកិច្ច

- ប្រជាជនប្រកបរបរចិញ្ចឹមជីវិតភាគច្រើនពីការធ្វើស្រែ និងខ្លះទៀតពឹងផ្អែកលើ តម្បាញ ជាងសំណង់ ជាងដែក និងរោងចក្រកាត់ដេរ
- ចំណូលជាមធ្យមគឺប្រមាណ ១៥០ ដុល្លារ ក្នុងមួយខែ ឬ ១៨០០ ដុល្លារ ក្នុងមួយឆ្នាំ

# សមិទ្ធផលសម្រេចបាន





ផលិតកម្មកសិកម្មបានកើនឡើងក្នុងរយៈពេល ប្រមាណជា ០៥ ឆ្នាំចុងក្រោយនេះ ដោយសារតែ ពូជថ្មី ជីសរីរាង្គ និងបច្ចេកវិទ្យាកសិកម្ម





សហគមន៍មានទឹកសម្រាប់ប្រើប្រាស់គ្រប់គ្រាន់នៅ គ្រប់រដូវកាល និងទប់ស្កាត់នូវហានិភ័យផ្សេងៗ

# សមិទ្ធផលសម្រេចបាន



មានសាលារៀនសម្រាប់កុមារបានសិក្សា
រៀនសូត្រ និងទទួលបានចំណេះដឹង



មានស្រះចិញ្ចឹមត្រីដើម្បីបង្កើនប្រាក់ចំណូលបន្ថែម

# សមិទ្ធផលសម្រេចបាន







មានពូជស្រូវមានគុណភាពល្អ
និងទទួលបានទិន្នផលខ្ពស់









មានសួនកុមារសម្រាប់លេងកម្សាន្ត

# សមិទ្ធផលសម្រេចបាន



មានមុខរបរបន្ថែមក្រៅពីកសិកម្ម



មានឥណទានសម្រាប់គាំទ្រដល់សមាជិកដើម្បី
ប្រើប្រាស់ក្នុងការងារកសិកម្ម និងបង្កើតមុខរបរបន្ថែម

# ៥. មេរៀន និងបទពិសោធន៍

## ២. ការអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច

- ភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ
- សហគមន៍បានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចពីក្រសួងអភិវឌ្ឍន៍ជនបទ



**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០៥១៥/១៩ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ៧កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៩

**គោរពជូន**
**ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ:** ករណីសំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក។

**យោង:** - លិខិតលេខ ១៨៧២/១៩ ល.ស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីសំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក របស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ
- សំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក របស់ លោក ខាត់ ខុម តំណាងសហគមន៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម **ឯកឧត្តមអភិបាល** នៃគណៈអភិបាលខេត្ត ជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រម ទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច កួយ ភូមិតាឡែក អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ដោយត្រូវគោរពតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិបាល** នៃគណៈអភិបាលខេត្ត មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមអភិបាល** នៃគណៈអភិបាលខេត្ត ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

# សមិទ្ធផលសម្រេចបាន







សហគមន៍ចូលរួមការងារអភិរក្សប្រពៃណី និងទំនៀមទម្លាប់

# សមិទ្ធផលសម្រេចបាន





សហគមន៍ចូលរួមក្នុងការងារអភិវឌ្ឍន៍ និងអភិបាលកិច្ចល្អ

# សមិទ្ធផលសម្រេចបាន



សកម្មភាពក្នុងការការពារ និងអភិរក្សប្រពៃណី និងវប្បធម៌របស់ជនជាតិដើមភាគតិច

# ៦.ទិសដៅការងារបន្ត

- ជំរុញការពិពិធកម្មសកម្មភាពសេដ្ឋកិច្ច តាមរយៈ **ការអភិវឌ្ឍភូមិគំរូ** ដោយផ្អែកលើសក្តានុពលតាមតំបន់នីមួយៗ
- បន្តជំរុញនិងលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- បណ្តុះបណ្តាលបំណិនជីវិតដល់គ្រួសារ និងសហគមន៍ជនជាតិដើមភាគតិច លើការងាររកទីផ្សារ សួនដំណាំគ្រួសារ របៀបធ្វើជីកំប៉ុស្ត ការត្រៀមបង្ការហានិភ័យក្នុងសហគមន៍
- ជំរុញ និងពង្រឹងសហគមន៍សន្សំប្រាក់ប្រព័ន្ធប្រតិបត្តិការផ្តល់សេវា
- បន្តសាងសង់ផ្សារជនបទនិងរៀបចំព្រឹត្តិការន៍តាំងពិពណ៌ផលិតផល
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា
- ពង្រឹងសមត្ថភាពដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងសហគមន៍ជនជាតិដើម

# ៦.ទិសដៅការងារបន្ត

- សិក្សាស្រាវជ្រាវពីតម្រូវការបណ្ដុះបណ្ដាលជំនាញមូលដ្ឋាន
- ផ្សព្វផ្សាយគោលនយោបាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដល់សហគមន៍ជនជាតិ
- ពន្លឿនការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដែលនៅសល់ និងរៀបចំចងក្រងសៀវភៅស្ដីពី ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់
- ផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ និងការបញ្ជ្រាបយែនឌ័រដល់សហគមន៍
- ពង្រឹងការពិនិត្យ តាមដាននិងវាយតម្លៃ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្ត

# ៧. សន្និដ្ឋាន

ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទបានលើកកម្ពស់ស្ថានភាព
សេដ្ឋកិច្ចជនបទ និងជំរុញសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទ
កាន់តែរស់រវើក និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ

ប្រជាជនជនបទទទួលបានការបណ្តុះបណ្តាលអំពីបំណិនជីវិត
និងពង្រីកមុខរបរ បង្កើនប្រាក់ចំណូលបន្ថែម មានទីផ្សារកសិ
ផលិតផលកាន់តែទូលំទូលាយ និងទទួលបានឥណទានដែល
មានអត្រាការប្រាក់សមរម្យ

បានធ្វើឲ្យការអភិវឌ្ឍក្នុងមូលដ្ឋានមានសន្ទុះប្រែប្រួលជាបន្ត
បន្ទាប់ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ជាពិសេសជីវភាពរស់
នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើងជាលំដាប់

ប្រជាពលរដ្ឋផ្លាស់ប្តូរឥរិយាបទ ពង្រឹងភាពជាម្ចាស់ និងធ្វើឱ្យ
សហគមន៍កាន់តែមានស្មារតីទទួលខុសត្រូវ ចេះការពារ និង
ថែទាំសមិទ្ធផលដែលមានក្នុងភូមិកាន់តែមានប្រសិទ្ធភាព។

# សូមអរគុណ !